Australian Government

NATIONAL
CERVICAL SCREENING
PROGRAM
A joint Australian, State and Territory Government Program

# ការពិនិត្យមាត់ស្បូននៅប្រទេសអូស្ត្រាលី

ការធ្វើតេស្តពិនិត្យមាត់ស្បូនរៀងរាល់ 5 ឆ្នាំម្តង គឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីការពារខ្លួនអ្នកប្រឆាំងនឹងជំងឺមហារីកមាត់ស្បូន – សូមកក់ទុកការណាត់ជួបមួយនៅថ្ងៃនេះ ជាមួយអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក។

## តើការពិនិត្យមាត់ស្បូនគឺជាអ្វី?

ការពិនិត្យមាត់ស្បូនពាក់ព័ន្ធនឹងការប្រមូលសំណាកមួយពីយោនី ឬមាត់ស្បូនរបស់អ្នក ដែលបន្ទាប់មកត្រូវគេយកទៅធ្វើតេស្តរកមើលសញ្ញានានានៃវីរុស human papillomavirus (HPV) – ដែលបណ្តាលជាការឆ្លងជំងឺទូទៅមួយ។ ករណីភាគច្រើននៃវីរុស HPV បាត់ទៅវិញដោយខ្លួនឯងក្នុងរយៈពេល 1 ទៅ 2 ឆ្នាំ។ ប្រសិនបើរាងកាយមិនបំបាត់វីរុស HPV ទៅវិញទេនោះ វាអាចបណ្តាលឱ្យមានការប្រែប្រួលកោសិកាមាត់ស្បូនមិនប្រក្រតី។ ប្រសិនបើទុកចោលដោយមិនបានរកឃើញ និង/ឬមិនបានព្យាបាលទេនោះ ការប្រែប្រួលទាំងនេះអាចវិវឌ្ឍទៅជាជំងឺមហារីកមាត់ស្បូន។

## ហេតុអ្វីវាមានសារៈសំខាន់?

ការពិនិត្យមាត់ស្បូន គឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីការពារខ្លួនអ្នកពីជំងឺមហារីកមាត់ស្បូន។ មនុស្សភាគច្រើនដែលកើតជំងឺមហារីកមាត់ស្បូនក្នុងប្រទេសអូស្ត្រាលី មិនដែលពិនិត្យ ឬមិនបានពិនិត្យជាទៀងទាត់ទេ។

មនុស្ស 9 នាក់ក្នុងចំណោមមនុស្ស 10 នាក់នឹងមានលទ្ធផលពិនិត្យដែលបង្ហាញពីហានិភ័យទាបនៃជំងឺមហារីកមាត់ស្បូន។ ប្រសិនបើមានការរកឃើញវីរុស HPV ឬភាពមិនប្រក្រតីនៅក្នុងអំឡុងពេលនៃការពិនិត្យ អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកអាចតាមដាន ឬព្យាបាលវាមុនពេលវាវិវឌ្ឍទៅជាជំងឺមហារីកមាត់ស្បូន។

## តើការពិនិត្យមាត់ស្បូនពាក់ព័ន្ធនឹងអ្វីខ្លះ?

អ្នកអាច **ជ្រើសរើស** ដើម្បីពិនិត្យដោយ៖

- ប្រមូលសំណាកយោនីរបស់អ្នកដោយផ្ទាល់ខ្លួន (ការប្រមូលដោយខ្លួនឯង) ឬ
- ឱ្យអ្នកផ្តល់សេវាកម្មថែទាំសុខភាពប្រមូលសំណាករបស់អ្នក។

ជម្រើសទាំងពីរគឺជាវិធីដែលមាន **ភាពត្រឹមត្រូវស្មើគ្នា និងប្រកបដោយសុវត្ថិភាព** ក្នុងការរកមើលវីរុស HPV និងជំងឺមាត់ស្បូនដែលពាក់ព័ន្ធ។

**ការប្រមូលខ្លួនឯង៖** អ្នកនឹងធ្វើកិច្ចការនេះដោយខ្លួនឯងនៅកន្លែងឯកជនមួយ (ឧទាហរណ៍៖ នៅពីក្រោយរបាំង ឬក្នុងបន្ទប់ទឹក) ហើយអ្នកប្រមូលសំណាកពីយោនីរបស់អ្នកដោយប្រើតម្បារចុងសំឡីមួយ។ អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក នឹងផ្តល់ឱ្យអ្នកនូវព័ត៌មានបន្ថែមដើម្បីជួយអ្នកក្នុងការប្រមូលសំណាកផ្ទាល់ខ្លួនរបស់អ្នក។ ពួកគេនឹងផ្ញើសំណាកទៅមន្ទីរពិសោធន៍ដើម្បីធ្វើតេស្ត ហើយប្រាប់អ្នកពីរបៀបដែលអ្នកនឹងទទួលបានលទ្ធផលរបស់អ្នក។

ប្រសិនបើគេមិនបានរកឃើញវីរុស HPV ទេនោះ អ្នកនឹងមានសេចក្តីស្ងប់ចិត្ត មុននឹងត្រឡប់ទៅធ្វើតេស្តពិនិត្យមាត់ស្បូនរបស់អ្នកម្តងទៀតក្នុងរយៈពេល 5 ឆ្នាំក្រោយ។ ប្រសិនបើគេរកឃើញវីរុស HPV អ្នកនឹងត្រូវធ្វើតេស្តបន្ថែមទៀត ឬនឹងត្រូវគេបញ្ជូនបន្តទៅគ្រូពេទ្យឯកទេសម្នាក់។



**សូមកក់ទុកការណាត់ជួបមួយនៅថ្ងៃនេះ ជាមួយអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក។**

Australian Government

NATIONAL CERVICAL SCREENING PROGRAM

A joint Australian, State and Territory Government Program

**ការប្រមូលដោយអ្នកផ្តល់សេវាកម្មថែទាំសុខភាព៖** នេះនឹងត្រូវបានធ្វើឡើងនៅកន្លែងឯកជនមួយ ជាមួយអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក ដោយគេត្រូវដាក់ប្រដាប់បើកមើលមាត់ស្បូនមួយទៅក្នុងយោនីរបស់អ្នក ហើយប្រើជក់តូចមួយដើម្បីប្រមូលសំណាកមួយពីមាត់ស្បូនរបស់អ្នក។ អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក នឹងផ្ញើសំណាកទៅមន្ទីរពិសោធន៍ដើម្បីធ្វើតេស្ត ហើយនឹងប្រាប់អ្នកពីរបៀបដែលអ្នកនឹងទទួលបានលទ្ធផលរបស់អ្នក។

## តើសំណាកដែលប្រមូលដោយខ្លួនឯង មានប្រសិទ្ធភាពដូចគ្នានឹងសំណាកដែលយកដោយអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់ខ្ញុំដែរទេ?

មានប្រសិទ្ធភាពពិតមែនហើយ។ ជម្រើសនៃការប្រមូលទាំងពីរនេះគឺជាវិធីមានប្រសិទ្ធភាពស្មើគ្នា និងប្រកបដោយសុវត្ថិភាពក្នុងការរកមើលវីរុស HPV និងជំងឺមាត់ស្បូនដែលពាក់ព័ន្ធ។

សំណាកមួយដែលយកដោយអ្នកផ្តល់សេវាកម្មថែទាំសុខភាព មានផ្ទុកកោសិកាមាត់ស្បូនជាច្រើន។ កោសិកាទាំងនេះអាចត្រូវបានគេធ្វើតេស្តរកមើលវីរុស HPV។ ប្រសិនបើគេបានរកឃើញវីរុស HPV សំណាកដដែលអាចត្រូវបានគេធ្វើតេស្តម្តងទៀត ដើម្បីពិនិត្យមើលថាតើមានការផ្លាស់ប្តូរប្រែប្រួលកោសិកាមិនប្រក្រតីណាមួយដែរឬទេ។

សំណាកដែលប្រមូលដោយខ្លួនឯងមានផ្ទុកកោសិកាយោនីជាច្រើន (មិនមែនជាកោសិកាពីមាត់ស្បូនរបស់អ្នកទេ) ហើយអាចត្រូវគេធ្វើតេស្តរកមើលវីរុស HPV។

ប្រសិនបើគេបានរកឃើញវីរុស HPV នៅក្នុងសំណាកដែលប្រមូលដោយខ្លួនឯង អ្នកនឹងត្រូវត្រឡប់ទៅជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកវិញ ដើម្បីឱ្យពួកគេប្រមូលសំណាកមួយ ឬអ្នកអាចត្រូវបានគេបញ្ជូនទៅជួបគ្រូពេទ្យឯកទេសម្នាក់ដើម្បីធ្វើតេស្តបន្ថែមទៀត។ អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក អាចនិយាយជាមួយអ្នកអំពីលទ្ធផលរបស់អ្នក ហើយថាតើវាមានន័យយ៉ាងណាដែរចំពោះអ្នក។

## តើខ្ញុំត្រូវការធ្វើតេស្តពិនិត្យមាត់ស្បូនទេ?

ប្រសិនបើអ្នក៖

- ជាស្ត្រី ឬអ្នកដែលមានមាត់ស្បូន
- មានអាយុចន្លោះពី 25-74 ឆ្នាំ ហើយ
- ធ្លាប់មានទំនាក់ទំនងផ្លូវភេទប្រភេទណាមួយ (ជាមួយនរណាម្នាក់ ដោយរាប់បញ្ចូលទាំងអ្នកដែលមានភេទដូចគ្នា)

អ្នកគួរតែធ្វើតេស្តពិនិត្យមាត់ស្បូនរៀងរាល់ 5 ឆ្នាំម្តង រហូតដល់អាយុ 75 ឆ្នាំ។

## តើខ្ញុំអាចធ្វើតេស្តពិនិត្យមាត់ស្បូននៅឯណា?

វេជ្ជបណ្ឌិត/GP, គិលានុបដ្ឋាក ឬអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកនៅមណ្ឌលសុខភាពសហគមន៍ ឬមណ្ឌលសុខភាពស្ត្រី, គ្លីនិកធ្វើផែនការគ្រួសារ និងគ្លីនិកផ្នែកសុខភាពផ្លូវភេទ ឬសេវាកម្មវេជ្ជសាស្ត្រជនជាតិដើមអាចផ្តល់ការពិនិត្យមាត់ស្បូនបាន។

សូមចងចាំថា អ្នកអាចស្នើសុំជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាព នូវភេទដែលអ្នកពេញចិត្តបានគ្រប់ពេល។

## ត្រូវការព័ត៌មានបន្ថែមឬ?

ប្រសិនបើអ្នកមានសំណួរណាមួយអំពីការធ្វើតេស្តពិនិត្យមាត់ស្បូន សូមកក់ទុកការណាត់ជួបមួយដើម្បីពិភាក្សាជាមួយអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក។

**ផងដែរនោះ អ្នកក៏អាច៖**

- ចូលទៅកាន់គេហទំព័រ **health.gov.au/NCSP** សម្រាប់ព័ត៌មានបន្ថែមអំពីការពិនិត្យមាត់ស្បូន
- ទូរសព្ទទៅលេខ **1800 627 701**
- ទូរសព្ទទៅសេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS National) តាមលេខ **13 14 50** ដើម្បីទទួលបានជំនួយជាភាសារបស់អ្នក។